# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ២៤

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៨៤

គ, ស. ១៩៤១

# ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ២៤

គណៈរដ្ឋមន្ត្រីនឹងសម្ដេចសង្ឃនាយកទាំងពីរគណៈ

បានអនុញ្ញាតហើយ

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

# បញ្ជីរឿង

ទំព័រ


១ — អំពីរបៀបបនាពុទ្ធសាសនា . . . . . . . . . . . . . . . . . . . . ៣

២ — អំពីពួកហុល្លង់ដើសនៅស្រុកខ្មែរ ក្នុងសម័យលង្វែក . . . . . . . . . . . . ៩

៣ — របៀបវិធីនិយាយអំពីទ្រង់ទ្រាយចក្រភពនិងច្បាប់សម្រាប់ត្រួតត្រាចក្រភព . . ១២

៤ — ពង្សាវតារក្រុងរោម ស្រង់យកអំពីគោលហេតុផ្សេងៗក្នុងពង្សាវតារលោក(តទៅ) ១៧

៥ — សេចក្ដីកត់ហេតុប្លែកៗ . . . . . . . . . . . . . . . . . . . . . . ២៣

៦ — រឿងព្រេងខ្មែរៈ "រឿងបុរសពីរនាក់ទៅបរបាញ់" . . . . . . . . . . . . ២៥


## រូបក្រៅរឿង


ហ្លួងព្រះបាង–វត្តស៊ៀងទុះលោក (ស្វគ៌ាលោក) នេះរូបទ្រៀងសក្ការបូជាខាងក្នុង
ព្រះវិហារ . . . . . . . . . . . . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES


| | Pages. |
|---|---|
| 1° L'art et la religion bouddhique | 3 |
| 2° Les Hollandais au Cambodge à l'époque de Long-Vék | 9 |
| 3° Système de formation de l'univers et lois générales de l'astronomie | 12 |
| 4° Histoire de Rome. Extrait de divers documents de l'histoire universelle (suite) | 18 |
| 5° Notes variées | 23 |
| 6° Conte populaire cambodgien inédit : Histoire de deux chasseurs partant à la chasse | 25 |

HORS-TEXTE

| | |
|---|---|
| Luang-Prabang. Vat Svankhalok. Autel à l'intérieur du Vihâra | 1 |

# ដំណឹងថ្មី

## អំពីព្រះរាជបណ្ណាល័យកម្ពុជា

ក្នុងខែមុននេះ យើងបានជូនដំណឹងដល់លោក-អ្នកហើយ ថាព្រះរាជបណ្ណាល័យបានបោះពុម្ពចេញផ្សាយអ្វីខ្លះ ដូចមានសេចក្តីយកការក្នុងទស្សនាវដ្តីលេខ ២២ ខែមុននេះរួចមកហើយ ។ ក្នុងខែនេះមានសៀវភៅថ្មីៗរបស់ព្រះរាជបណ្ណាល័យចេញផ្សាយថែមទៀត គឺ:

១ – <u>ច្បាប់ក្រម</u> ជាច្បាប់ចាស់មួយរបស់ខ្មែរប្រែកបដោយពាក្យកាព្យ ដែលអ្នកប្រាជ្ញជាតិខ្មែរបានតែងទុកមកយូរហើយ ។ ច្បាប់នេះកូនខ្មែរពីដើមធ្លាប់តែទន្ទេញចាំមាត់តល់គ្នា សៀវភៅនេះដំថ្លៃ ១ ក្បាល ០៛.១០ ។

២ – <u>ច្បាប់ត្រីនេតិ</u> ជាច្បាប់ពាក្យកាព្យ ១ ទៀតជាស្នាដៃអ្នកប្រាជ្ញជាន់ដើមដែរ មានទុកទូន្មានល្អៗ ជាគ្រឿងប្រដាប់សតិបញ្ញារបស់កុមារកុមារីជាតិខ្មែរ ដំថ្លៃ ១ ក្បាល ០៛.១៥ ។

៣ – <u>ច្បាប់រាជនីតិ</u> ជាច្បាប់សម្រាប់ទូន្មានក្សត្រាក្សត្រី និងនាហ្មឺនសព្វមុខមន្ត្រី ឲ្យចេះដឹងមុខក្រសួងរបស់ខ្លួន ដែលត្រូវធ្វើត្រូវប្រព្រឹត្តទាំងប៉ុន្មាន ជាសេចក្តីពាក្យកាព្យងាយស្តាប់ ដំថ្លៃ ១ ក្បាល ០៛.១៥ ។

៤ – <u>មួយពាន់មួយយប់</u> ភាគ ៩ ជារឿងអារ៉ាប់ប្រែចេញមកពីភាសាបារាំងសែស រឿងនេះពីរោះអស្ចារ្យដូចម្តេចៗ ខ្លះនោះសឹងលោកអ្នកបានជ្រាបស្រាប់ហើយ សៀវភៅនេះដំថ្លៃ ១ ក្បាល ០៛.២៥ ។

ហេតុដូច្នេះ សូមអស់លោក-អ្នកអញ្ជើញទៅជាវមើលតាមត្រូវការ សឹងមានចំណាយជានិច្ចនៅព្រះរាជបណ្ណាល័យកម្ពុជា និងកន្លែងលក់សៀវភៅរបស់ព្រះរាជបណ្ណាល័យទូទៅ ។



ហ្លួងព្រះបាង— វត្តស៊ុនខះលោក (ស្ទូតាំលោក) នេះរូបគ្រឿងសក្ការបូជាខាងក្នុងព្រះវិហារ ។

# អំពីរបៀបបូជាក្នុងព្រះពុទ្ធសាសនា

ព្រះពុទ្ធជាម្ចាស់ទ្រង់បានជ័យជំនះឈ្នះអស់ទាំងអគតិធម៌របស់មនុស្សដែលនៅជុំវិញព្រះអង្គ ហើយមនុស្សអស់នេះនាំគ្នាមកគោរពបូជាព្រះអង្គយ៉ាងខ្ពង់ខ្ពស់ ហើយនាំគ្នាទុកដាក់ព្រះអង្គដូចជាទេវៈ ទ្រង់មិនជឿអំណាចទិព្វឬអំណាចហួសពីធម្មតាវិស័យក្នុងកិច្ចការនានានៅក្នុងលោកនេះ ។ ចុះព្រះពុទ្ធជាម្ចាស់ទ្រង់បានសម្រេចសេចក្ដីពិតដូចម្ដេច? គឺថាព្រះអង្គបានលុះនោះ មិនមែនសម្រេចដោយសេចក្ដីប៉ុនប៉ងនឹងសេចក្ដីព្យាយាមរបស់អ្នកដទៃទេ ទ្រង់បានសម្រេចដោយសេចក្ដីព្យាយាមរបស់ព្រះអង្គ ព្រះពុទ្ធជាម្ចាស់ទ្រង់បង្ហាញផ្លូវឲ្យពួកសាវកប្រតិបត្តិតាម កាលព្រះអង្គទ្រង់ព្រះជន្មនៅឡើយ ពួកសាវកបានសម្រេចព្រះអរហត្តតាមព្រះបរមគ្រូ ហើយលទ្ធិរបស់ព្រះអង្គមិនយូរប៉ុន្មាន បានទៅជាសាសនាតាំងនៅលើគោលការណ៍មួយ ដែលធ្វើមនុស្សប្រតិបត្តិតាមឲ្យបានសម្រេចសេចក្ដីពិតបាន ដោយមិនបាច់មានជំនួយអំពីអានុភាពទេវតា ជាវេលាច្រើនសតវត្សរ៍ ចំនួនព្រះអរហន្តក៏កាន់តែកើនច្រើនឡើង វត្តអារាមនឹងវិហារក៏ដេរដាសពាសពេញដោយគំនូររូបផ្សេងៗ សុទ្ធតែជារឿងរ៉ាវក្នុងព្រះពុទ្ធសាសនា ជាបែបគំនូរគូរដោយថ្នាំក៏មានជាបែបចម្លាក់ក៏មាន ។

បណ្តារូបដំណាងដែលគេចាប់ធ្វើឡើងជាដំបូងៗ ដើម្បីគោរពបូជានោះ គេមិនទាន់ហ៊ានកសាងជាព្រះពុទ្ធរូបដូចជារូបមនុស្សធម្មតាទេ ប៉ុន្តែរូបដំណាងព្រះអង្គគេសាងជារូបវត្ថុនីមួយៗ ដែលនៅនឹងព្រះអង្គឬក្បែរព្រះអង្គ ដូចជាដើមពោធិព្រឹក្ស ព្រះធម្មចក្រ ស្នាមព្រះពុទ្ធបាទជាដើម ។ ប៉ុន្តែតមកសេចក្តីត្រូវការបង់បានព្រះពុទ្ធរូបកាន់តែចំរើនបន្តិចៗឡើង ទើបកើតមានព្រះពុទ្ធរូបកាន់តែចំរើនឡើងជាដំបូងៗ ដែលគេបានមកអំពីខេត្តគន្ធារៈ តាំងក្បាច់ចម្លាក់ទង់អង្គបដិមា ជាបែបបនាក្រិក ដែលគេបានចម្លងយកតាំងគ្រឿងសំលៀកបំពាក់នឹងទ្រង់ទ្រាយមុខ លុះអំណើះកាលតមក ទើបមានបែបផែនឥណ្ឌាកើតឡើង ហើយព្រះពុទ្ធរូបមានទ្រង់ទ្រាយជិតក្បែររូបរាជកុមារ ឬអង្គរបស់ប្រទេសឥណ្ឌា តែទ្រង់ត្រៃចីវរតាមបែបសមណៈ ។ ឯរបៀបលក្ខណៈរបស់ព្រះពុទ្ធរូបនេះ គេធ្វើជារបៀបទៀងទាត់ងាយយល់ងាយស្គាល់ ហើយរបៀបគំនូរព្រះពុទ្ធរូបខ្វះទៀតសោត ដែលមាននៅក្នុងទ្វីបអាស៊ីនេះ ក៏មានលក្ខណៈនឹងនួនដូចគ្នាតែបែបមួយ ហើយជារូបសមរម្យនឹងទៀងទាត់ល្អណាស់ ដែលគេបានកសាងជាព្រះពុទ្ធរូបទ្រង់ស្តិតឬទ្រង់ធំក៏មាន ។

ក៏ព្រះពុទ្ធរូបផ្សេងៗ តាំង ៣ ប្រភេទនេះ ត្រង់ដែលទ្រង់គង់មាន ៣ បែបដែលហៅថាមុទ្រៈ សំដែងព្រះអាការៈផ្សេងគ្នាដោយព្រះហស្តៈ

ភូមិស្បស៌សិរះមុទ្រ: ព្រះពុទ្ធទ្រង់បង្អុលផែនដី

ធ្យានមុទ្រ: ព្រះពុទ្ធទ្រង់គង់បំពេញសមាធិ

ចក្រមុទ្រ: ព្រះពុទ្ធទ្រង់សំដែងធម៌ ។

ឯព្រះពុទ្ធរូបទ្រង់ស្ថិតឈរច្រើនតែមានចីវរឃ្លុំព្រះអង្គទាំងសងខាង ព្រះបាទដាក់គម្រៀបគ្នាស្មើ ។ នៅមានព្រះពុទ្ធរូប ១ បែបទៀត ជារូបដំណាងព្រះពុទ្ធទ្រង់ធ្វើដំណើរចារិក តែព្រះពុទ្ធរូបនេះគេឃើញមានតែក្នុងប្រទេសលាវនិងប្រទេសភូមា ។ ព្រះពុទ្ធរូបផ្តុំឃើញតែមានលក្ខណៈនឹងទឹកព្រះភក្ត្រជារូបដំណាងកាលព្រះបរមគ្រូនៅក្នុងវ័យក្មេង មិនមែនជាព្រះពុទ្ធមានព្រះជន្មាយុច្រើនដល់ ៨០ ឆ្នាំហើយទេ គេច្រើនតែនិយមធ្វើបែបមួយនេះទូទៅ ។

លោកហ្វា-ហៀន ក៏បាននិយាយអំពីព្រះពុទ្ធរូបឈើធ្វើពីខ្លឹមចន្ទន៍ ដែលព្រះបាទប្រសេនជិតដែនកោសលទ្រង់ឲ្យជាងឆ្លាក់ជារូបដំណាងព្រះពុទ្ធអង្គ ហើយទ្រង់យកទៅដំកល់ទុកក្នុងជេតវនវិហារក្រុងសាវត្ថី ជាព្រះរូបព្រះបដិមាតាំងជាជំនួសព្រះពុទ្ធជាម្ចាស់កាលស្តេចឡើងទៅកាន់ស្ថានសួគ៌ជាន់តាវតិង្ស ។ លុះព្រះពុទ្ធអង្គស្តេចចុះពីស្ថានសួគ៌វិញ ទ្រង់មានព្រះបន្ទូលថា រូបនេះដូចជារូបព្រះអង្គពិតប្រាកដមែន ។ ក្រោយមកបន្ទាប់កើតភ្លើងឆេះវត្ត ព្រះពុទ្ធរូបគេបានជួយរួចពីភ្លើងឆេះ ហើយដល់វេលាក្រោយទៅ គេក៏នាំយកទៅទុកក្នុងទីនោះដដែលវិញ ។

លោកហៀន-ឆាងក៏បាននិយាយអំពីព្រះពុទ្ធរូប ១ អង្គទៀតធ្វើពីខ្លឹមចន្ទន៍ដែរ តែជាព្រះរូបធំជាងរូបពិតរបស់ព្រះអង្គច្រើន រូបនេះព្រះបាទឧទាយនក្រុងកោសម្ពីឲ្យជាងឆ្លាក់ឡើង ។ លោកអ្នកធុតង្គជាតិចិន បានចម្លងយកបែបព្រះពុទ្ធរូបនេះទៅទុកនៅស្រុកចិនផង ។ លោកហៀន-ឆាង បានឃើញទីក្រុងបាក់បែកមួយ តែព្រះពុទ្ធរូបនៅគង់ទ្រង់ល្អទាំងអស់ក្នុងវិហារចាស់មួយ ។

ក្នុងប្រទេសភូមានិងលង្កា បណ្តាវត្តអារាមច្រើនតែមានរូបភាពព្រះពុទ្ធ ហើយគេនិយមធ្វើព្រះអគ្គសាវកទាំងពីរអង្គ លុតជង្គង់ប្រណម្យនៅខាងមុខព្រះពុទ្ធរូប ហើយនឹងព្រះពុទ្ធដែលកន្លងមកហើយចំនួន ២៨ អង្គ ព្រមទាំងព្រះពុទ្ធបាទផង ។ ពួកឧបាសកឧបាសិកានាំគ្នាមកគោរពនមស្ការ ហើយសូត្រធម៌ថ្វាយបង្គំនៅចំពោះមុខរូបអស់នេះ ។ ចិត្តគំនិតរបស់សាសនិកជនក្នុងប្រទេសអស់នេះ គេមិនមានចេតនាថ្វាយបង្គំចំពោះរូបអស់នោះទេ ឯរូបអស់នោះគ្រាន់តែជាគ្រឿងរំឭកដល់កិច្ចការផ្សេងៗនឹងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ប៉ុណ្ណោះ ។

ក្នុងលទ្ធិមហាយានច្រើននិយមសាងរូបទេវតាជាច្រើន គឺរូបព្រះអរហន្ត, រូបព្រះពុទ្ធ, រូបព្រះពោធិសត្វសឹងមានចំនួនច្រើនជាអនេក ។ ពួកវត្តយួន, វត្តចិន, វត្តជប៉ុននឹងវត្តទីបេតាំង ច្រើនតែកុះករដោយរូប

ផ្សេងៗ កប់ជាច្រើនយ៉ាង ហើយច្រើនលើសពីចំនួនមនុស្សដែលទៅប្រជុំនមស្សការនោះទៀត ។

របៀបចេតិយព្រះពុទ្ធសាសនាស្ទុះឡើងកាន់ដំណែងយ៉ាងសំខាន់ក្នុងពង្សាវតាររបស់លោក បណ្តាបុរាណស្ថានដែលសេសសល់ពីបាក់បែកខ្ទេចខ្ទីទៅតាំងពីបុរាណ គេអាចពោលថាជារបស់ល្អឯកក្នុងសិល្បកម្មពុទ្ធ-សាសនា ។ កាលអំពីពុទ្ធសករាជ ២៥០ ដល់ ៦០០ នោះថ្មសិលាត្រូវយកមកប្រើការក្នុងការកសាងជាវត្ថុ មុនដំបូងគេប្រើឥដ្ឋធ្វើការកសាង នៅក្នុងសម័យព្រះបាទអសោកគេប្រើឈើធ្វើការដែរ ឯជាវត្ថុសំខាន់ៗរបស់ព្រះពុទ្ធសាសនាគឺ:

១ - ស្តូបមានទ្រង់ទ្រាយកងក្រអាញ កសាងដោយឥដ្ឋ សម្រាប់បញ្ចុះព្រះសារីរិកធាតុរបស់ព្រះពុទ្ធជាម្ចាស់ ។ មានស្តូបមួយដែលមានគេស្គាល់ច្រើននោះហៅថា សញ្ចី ប្រហែលកសាងក្នុងពុទ្ធសករាជ ៧៥០ ។

២ - ចេតិយប្លុកខ្ទង់ដែលប្រជុំដោយសសរ នៅត្រង់កណ្តាលមានស្តូបតូច នៅពីខាងលើមានដោតឆត្រធ្វើពីឈើផង តែបាក់បែកបាត់បង់ទៅជាយូរអង្វែងហើយ ។ តាំងអំពីពុទ្ធសករាជ ២៥០ ដល់ ១១៥០ មានជាវត្ថុជាចំនួនច្រើន ដែលគេបានកសាងឡើងនៅក្នុងរអាងគូហាតាំងឡាយ ។ ជាវត្ថុដាច់ចាស់ជាងបំផុត ដែលកើតឡើងក្នុងរជ្ជសម័យ

ព្រះបាទអសោកនោះនៅក្បែរគយា ដែលបុរាណជាងគេ គួររាប់យកចេតិយអដ្ឋៈដែលមានរូបព្រះពុទ្ធ ដែលជាដំណាងកន្លងលក្ខណអាការៈផ្សេងៗគ្នា ជារូបគំនូរនិងរូបចម្លាក់ ។

៣ – រួចតមក មានវិហារដែលជាបុរាណស្ថានដូចជាចេតិយដែរ ដែលកើតតាំងអំពីពុទ្ធសករាជ ២៥០ ដល់ ១១៥០ ។ ឯរូបគំនូរព្រះពុទ្ធ ដែលជារបស់មាននៅនឹងបុរាណស្ថានចាស់បំផុតក្នុងប្រទេសឥណ្ឌា ប្រហែលកើតឡើងតាំងអំពីពុទ្ធសករាជ ៦៥០ ។ គេឃើញគំនូរព្រះពុទ្ធអស់នោះសុទ្ធតែមានរស្មីមួយព័ទ្ធជុំវិញព្រះសិរដែលជាបែបរចនារបស់គន្ធារៈ គឺគំនូរគូររូបជាតកនិងអស់ទាំងរឿងរ៉ាវសំខាន់ៗ ក្នុងពុទ្ធប្រវត្តិ ។ នៅប្រទេសឥណ្ឌាក៏ដូចជាកោះលង្កា បុរាណស្ថានច្រើនតែខូចខាតទៅដោយអាកាសសើមនិងសត្វប្រចៀវ ទើបគេយល់ថារូបគំនូរផ្សេងៗដែលមាននៅតាមជញ្ជាំងបុរាណស្ថានអស់នោះរលុបសាបសូន្យអស់ទៅហើយ ។

# អំពីពួកហុល្លង់ដេស៍នៅស្រុកខ្មែរ

មានជនជាតិបារាំងសែសឈ្មោះលោកកាបាតុង បានរួបរួមឯកសារ (Documents) ទាំងពួងដែលបាននិយាយអំពីការប្រស្រ័យនៃពួកហុល្លង់-ដេស៍នឹងស្រុកខ្មែរ កាលពី ព. ស. ២១៧៩ នោះថា ពួកហុល្លង់ដេស៍បានទិញកញ្ចាន, ប៉េខ, ឈើព្រហូត, ក្រវាញ, ក្ងុក, សាច់ជ្រូក, ខ្លាញ់ជ្រូក, មាសខ្លះនឹងសត្វឈ្លូសអំពីស្រុកខ្មែរ ។

កន្លងសម័យនោះ ស្រុកខ្មែរមានផ្លូវដំនួញនឹងជនជាតិតាំងប្រទេសតែបន្តិចបន្តួច ចំណែកខាងស្រុកសៀមវិញ បានផ្លាស់ប្តូរដំនួញដួញប្រែនឹងពួកជនជាតិតាំងប្រទេសជាច្រើន ។ ពួកអ្នកដំនួញហុល្លង់ដេស៍ដឹងថាប្រទេសកម្ពុជានៅជិតដែនកូសាំងស៊ីន ហើយដឹងថាក្រុងលង្វែកនៅលើមាត់ទន្លេមេគុង (ការពិតនៅលើដៃទន្លេសាប) មានព្រះរាជវាំងហ៊ុំព័ទ្ធខ្លោមជុំវិញដោយកំពែងឈើ ។ តួវាំងធ្វើដោយឈើទាំងអស់លាបថ្នាំបិទមាស នៅខាងក្នុងវាំងនេះមានរបស់ល្អៗធ្វើពីមាសនឹងប្រាក់ ។ ជុំវិញព្រះរាជវាំងមានពយកាំភ្លើងធំ ២៤ លាបថ្នាំពណ៌ខៀវនឹងលាបម្រ័ក្សណ៍ខ្មៅ ។ គេបានជួបប្រទះនឹងពួកជប៉ុន, ពទុគេស, ពួកកូសាំងស៊ីន ពួកចាម មកនៅធ្វើជំនួញនៅលង្វែក ពីព្រោះស្រុកខ្មែរជាប្រទេសសំបូណ៌ដោយស្រូវ, ពាសាពាសី, កន្ទេល, សូត្រ, ផ្តៅ, ជ័រ, ល័ខ

ក្រមួន, ភាជន៍ស្ពាន់, សេះ, កុយរមាស, ស្បែកក្ដាន់, ។ ពួកហុល្លង់ដេស៍កត់សំគាល់ថា នៅស្រុកខ្មែរមានចំនួនស្ទឹងជាច្រើនហើយមានមនុស្សតិច ៗ ក្នុងពុទ្ធសករាជ ២១៦៤ ដល់ទៅ ២១៧៥ ត្រូវស្ដេចស្រុកសៀមលើកទ័ពមកវាយស្រុកខ្មែរ តាមផ្លូវជើងគោកនិងជើងទឹក ប៉ុន្ដែមិនសម្រេចឡើយហើយត្រូវពួកខ្មែរវាយថយទៅវិញ លុះដល់មក ព. ស. ២២៥០ ស្ដេចស្រុកខ្មែរត្រូវស្ដេចស្រុកកូសាំងស៊ិនលើកទ័ពមកច្បាំង (ស្ដេចយួនទេដឹង?) ។

សំណាំចុតហ្មាយរាជការជាដំបូងពីខាងស្រុកខ្មែរ គឺព្រះហត្ថលេខារបស់ស្ដេចស្រុកខ្មែរ មានទៅដល់គូវែរណើរហ្សេណេរ៉ាល់នៅប្រទេសស័កកាត្រា ដោយព្រះបាទធម្មរាជាធិរាមាធិបតី (ក្នុង ព. ស. ២១៧២-២១៨១) បានទ្រង់អនុញ្ញាតឲ្យពួកហុល្លង់ដេស៍សង់ឃ្លាំងដាក់ទំនិញមួយនៅស្រុកពញាលឺ ។ កើតមានការប្រណាំងប្រជែងគ្នាខាងផ្លូវជំនួញយ៉ាងខ្លាំង រវាងពួកអ្នកជំនួញតាំងប្រទេស ពួកជប៉ុនជាទីប្រោសប្រាណរបស់ស្ដេច ហើយពួកចិនជាអ្នកជំនួញដែលខំខ្មីឃ្មាតបំផុត ហើយបែកសាយចេញទៅគ្រប់ៗតំបន់ក្នុងប្រទេស ។ មានជនជាតិសៀមជាចំនួនតិច

ទេ ដែលគេស៊ីបំពោះខាងផ្លូវជំនួញនៅស្រុកឡាវ ។ មានជនជាតិហុល្លង់-ដេសជាអ្នកជំនួញម្នាក់ ដែលព្រះវររាជជននីទ្រង់ជុបលៀងទំនុកបំរុងកប់អានដូចជាព្រះរាជបុត្ររបស់ទ្រង់ ។ អស់ទាំងសំបុត្រចុតហ្មាយឆ្លើយឆ្លង រវាងព្រះរាជវាំងនឹងពួកហុល្លង់ដេសគេធ្វើជាភាសាជ្វាចាម ដល់មកក្នុង ព. ស. ២២២២ ទើបមានសំពៅមួយយ៉ាងធំបើកចេញទៅក្រុងបាតាវីយ៉ា ព្រមទាំងព្រះរាជសារដែលតែងជាភាសាចាម សឹងមានសេចក្ដីថា “ក្រុងបាតាវីយ៉ានឹងក្រុងកម្ពុជាទុកជាប្រទេសជាតិតែមួយ” ។

# អំពីរបៀបរឿងនិយាយអំពីទ្រង់ទ្រាយចក្រវាឡ
# និងរឿងដែលពោលពីច្បាប់ត្រួតត្រាចក្រវាឡ

ចក្រវាឡរឿង ជារឿងមួយនិយាយអំពីដើមកំណើតនៃចក្រវាឡ ។ បណ្ដាប្រជាជនដែលបានដល់នូវសេចក្ដីចំរើនខ្លះហើយ បាននាំគ្នាយកចិត្តទុកដាក់ទឹងប្រស្នានេះ ហើយរបៀបរៀបចំនៃការកសាងចក្រវាឡក៏មានបែបផ្សេងៗគ្នា សឹងប្រព្រឹត្តទៅតាមជំនឿរបស់ប្រជាជនក្នុងសម័យនោះ ។

តាមពួកពុទ្ធសាសនិកជន (អក្សរសាស្ត្រសំស្ក្រឹត) ថា ការបែកផ្សេងនៃលោកនេះកើតមកអំពីកម្ម ចំណោះរឿងទាំងនេះគេហៅថា "ចក្រវាឡរឿង" ជារឿងដែលនិយាយពន្យល់អំពីដើមកំណើតនៃការកសាងនិងសេចក្ដីវិនាសនៃលោកនេះ ។ តាមពួកសវិស្ដិវាទិនពោលថា មានលោក ២ គឺ ១– លោកជាទីរួបរួមឬភាជនលោក ២– លោកជាទីនៅនៃសត្វនិងមនុស្សឬសត្វលោក ។

ឯសត្វលោកនេះចែកចេញជា គឺ ១– សត្វឥតរូប ឬអរូបៈដែលមាននៅទីដទៃ ហើយមិនមាននៅក្នុងភាជនលោកទេ ២– សត្វមានរូបឬរូបិននៅក្នុងចំណែកជាន់ខ្ពស់នៃរូបធាតុ ៣– ពួកសត្វដែលមានរូបនិងមានកង់ស្កឹមស្កៃ នៅក្នុងលោកទាបៗ ចុះទៅក្រោមតាមក្រុមពួករបស់ខ្លួន ហើយជាពួកសត្វបរិភោគកាមនៅក្នុងកាមធាតុ ។

ពួកសត្វលោកទាំងពួងចែកចេញជា ៥ ពួក ល្អ ២ ពួក អាក្រក់ ៣ ពួក ហៅថាគតិ ឬប្រភេទរបស់សង្សារវដ្ត ។ ប្រភេទអស់នេះចែកចេញជាច្រើនពួកទៅទៀត គឺជាពួកទេវតាមាន ៣ ពួក ជាពួកមនុស្សមាន ៤ ពួក ជាពួកប្រេតមានតែមួយប្រភេទដូចជា សត្វតិរច្ឆានទាំងឡាយ ឯពួកសត្វដែលត្រូវមានទោស ( សត្វនរក ) ចែកចេញជា ៨ ប្រភេទ ត្រូវជាជាន់តាមជាតុមាន ២០ ប្រភេទឬ ២០ អន្លើ ។ គម្ពីរជាន់ក្រោយៗមក កាន់តែមានរឿងរ៉ាវច្រើនៗ ឡើងជាងគម្ពីរជាន់ចាស់ ( គម្ពីរបាលី ) សឹងមានសេចក្ដីពេយពយ ហើយសេចក្ដីអធិប្បាយពន្យល់អំពីរឿងនេះ ក៏មានសេចក្ដីសំខាន់តែបន្តិចបន្តួចទេ ។

ឯរឿងរ៉ាវដែលគេបានឃើញក្នុងគម្ពីរបាលីចាស់ៗឡើងទៅមុនសម័យពុទ្ធកាលនោះ តាមគម្ពីរអស់នោះសំដែងថា ធាតុមាន ៤ ប្រភេទឬដែលហៅថា មហាភូតទាំង ៤ គឺ ទឹក ដី ភ្លើង ខ្យល់ ដែលផ្សំគ្នាជាភូតរូបឡើង ។ (ដល់តមកគេបានបន្ថែម) ធាតុទី ៥ មួយទៀត ហៅថា អាកាសធាតុ ។

ចក្រវាឡតូចៗ នោះជាចំណែកមួយ ដែលមានពោលទុកក្នុងភូមិ-សាស្ត្រជាន់ចាស់របស់ឥណ្ឌាបុរាណ ថានៅកណ្ដាលពិភពនេះ មានភ្នំមេរុឬភ្នំព្រះសុមេរុៗនេះជាឈ្មោះភ្នំហិមាល័យ ព្រះអាទិត្យតែងគោចរ

ទៅជុំវិញភ្នំនេះ ហើយនៅលើភ្នំអស់នេះ ជាទីស្ថិតនៅនៃពួកទេវតា នៅខាងត្បូងភ្នំនេះ ជាទីតាំងនៃប្រទេសឥណ្ឌា ឬជម្ពូទ្វីប នៅទិសដទៃជុំវិញភ្នំនេះក៏មានទ្វីបឯទៀតៗដែរ ។ តអំពីនោះទៅ ទើបដល់ទៅវាយុមណ្ឌល: ដែលមានពពកកកកើតទៅជាទឹក ហើយបង្ហូរចុះទូវសមុទ្រទឹក-សមុទ្រមាស ។ សមុទ្រនេះកាលត្រូវខ្យល់បក់បោក កើតទៅជាអាបមណ្ឌល ហើយនៅលើនោះមានដីមាសអណ្តែតឡើងដែលហៅថាកាញ្ចនមណិភូមិ នៅលើផែនដីនោះមហាមេឃតែងបង្អុរចុះទូវពេជ្រនីល, ចិន្តា, ដី, ទឹក, ដែក តែងមាននៅជុំវិញភ្នំព្រះសុមេរុ ហើយមានភ្នំទាំង ៨ ជាប់ឃ្លាតចេញពីគ្នាដោយមហាសមុទ្រនិងកោះទាំងឡាយ ។ ទ្វីបទាំងឡាយទើបកើតមានដីល្អដ៏ជាតិតាំងនៅលើដីមាសឬបរិវេណមាស ។

នៅទិសខាងកើតមានបុព្វវិទេហទ្វីប ជាទ្វីបគុះករដោយទីក្រុងនិងស្រុកភូមិណែនណាន់តាន់តាប់ ពួកដែលនៅលើទ្វីបនេះមានអាយុ ២៥០ ឆ្នាំ ហើយទំរង់មុខរបស់មនុស្សនៅទ្វីបនេះ ដូចទ្រង់ទ្រាយទ្វីបរបស់ខ្លួន គឺទ្រមង់ខែ ១ ចំហៀង ។

នៅទិសខាងត្បូងមានជម្ពូទ្វីបនេះជាទីកើតនៃព្រះពុទ្ធជាម្ចាស់ មនុស្សទាំងឡាយនៅលើទ្វីបនេះមានអាយុមិនហួសពី ១០០ ឆ្នាំទេ ។

នៅទិសខាងលិច មានអបរគោយានទ្វីប ។ នេះនៅចំណែកទិសខាងលិច ឯមនុស្សទាំងឡាយនៅក្នុងទ្វីបនេះមានអាយុ ៥០០ ឆ្នាំ ។

នៅទិសខាងជើងមានឧត្តរកុរុទ្វីប ។ នេះមិនមានទីក្រុង មិនមានស្រុកភូមិទេ មនុស្សទាំងឡាយនៅក្នុងទ្វីបនេះមានអាយុ ២០០០ ឆ្នាំ ។

ឯស្ថាននរកដែលមានភ្លើងឆេះជានិច្ចនោះ នៅឆ្ងាយអំពីខាងត្បូងបំផុតនៃជម្ពូទ្វីប ភប់ដោយចំនួនជាច្រើនលានគីឡូម៉ែត្រ ។ រណ្តៅនរកអវិចីនោះនៅទិសខាងត្បូងផុតហើយនៅខាងលើនរកនេះមាននរក ៧ អន្លើទៀតហៅថា សញ្ជីវនរក នៅទីនេះមានខ្យល់បក់មកត្រូវសត្វដែលស្លាប់ទៅ ឲ្យមានជីវិតរស់ឡើងវិញ មានខ្សែខ្មៅ ( កាឡសុត្ត ) សម្រាប់វែតកាត់សត្វនរកឲ្យដាច់ជាកំណាត់ៗ សង្ឃាតនរកនៅក្នុងចន្លោះភ្នំដែលទង្គិចទង្គុកគ្នាជានិច្ច រោរុវនរកជាស្ថានដែលមានសត្វនរកស្រែកទ្រហោយំខ្លាំងឡើងទៅទៀត តាបណនរក ជាស្ថាននរកដែលមានកំដៅកេលពល ប្រតាបននរក ជាកន្លែងដែលក្តៅខ្លាំងណាស់ ។

នៅមាននរកធំ ៨ រណ្តៅទៀត នៅក្នុងទីងងឹតស្លុប នៅខាងលើស្ថាននរក ជាស្ថានពួកសត្វតិរច្ឆានដែលយើងបានឃើញនៅក្នុងស្ថានមនុស្សលោកនេះខ្លះដែរ តែមិនមាននៅក្នុងស្ថានទេវលោកសោះឡើយ ។

ឯពួកប្រេតរមែងមានពាសពេញក្នុងស្ថានមនុស្សលោក តែដោយច្រើននោះ ពួកប្រេតនៅក្នុងស្ថានយមលោកជាអាណាចក្រមួយមាន ៣៦ ខែត្រ ។ អាយុប្រេតនោះ ៥០០ ឆ្នាំ ហើយក្នុង ១ ថ្ងៃរបស់ប្រេតប្រហែល ៣០ ថ្ងៃក្នុងស្ថានមនុស្សលោក ។

ពួកអសុរនៅក្នុងគុហាបាតភ្នំព្រះសុមេរុ ក្រោមទឹកសមុទ្រទៅទៀត នៅទីនោះមានក្រុងធំ ៤ មានស្តេចសោយរាជ្យ ៤ អង្គដែរ តែពួកអសុរច្រើនតែនាំគ្នាលើកទ័ពចេញពីភពខ្លួន ឡើងទៅច្បាំងតទល់នឹងពួកទេវតា ៣៣ អង្គ (ស្ថានត្រៃត្រិង្ស) ពួកកងទ័ពអសុរនេះ មានពួកយក្សជាទ័ពស្រួច ឯពួកយក្សមួយពួកនៅក្រោមដី (ស្ថានបាតាល) ឯពួកយក្សឯទៀតៗនៅលើដី ។ ឯភ្នំព្រះសុមេរុនេះមានស្ថាន ៤ អន្លើ នៅលើស្ថានទី ៤ មានមហារាជ ៤ អង្គ ជាស្តេចប្រចាំទិសទាំង ៤ ទុកដូចជាទេព្ដាដែរ ហើយមហារាជទាំង ៤ អង្គនេះមានព្រះជន្ម ៥០០ ឆ្នាំ មួយថ្ងៃក្នុងស្ថាននេះជា ៥០ ឆ្នាំក្នុងស្ថានមនុស្ស ។

មហារាជមួយអង្គៗនោះមានបរិវារជាចំនួនច្រើន សុទ្ធតែជាពួកភ្លេងដែលហៅថាគន្ធព្វៗ មិនមែនជាពួកទេវតាទេ ។ នៅពាក់កណ្តាលផ្លូវដែលឡើងទៅភ្នំព្រះសុមេរុ មានពួកទេវតារបស់ព្រះអាទិត្យព្រះចន្ទនិងពពួកផ្កាយផ្សេងៗ នៅកំពូលភ្នំព្រះសុមេរុជាស្ថានតាវតិង្ស ព្រះឥន្ទជាស្តេចទេវតា សោយរាជ្យនៅលើស្ថាននេះ ទីក្រុងមានព្រះរាជវាំងជ័យ ។ ឯអាយុទេវតានៅស្ថាននេះកំណត់ ១០០០ ឆ្នាំ ហើយក្នុង ១ ថ្ងៃប្រហែល ១០០ ឆ្នាំស្ថានមនុស្ស ។ នៅមានស្ថានសួគ៌ ៤ ជាន់ទៀតជាស្ថានបរិភោគកាមគុណដែរ ។

ឯស្ថានព្រហ្មនោះជាទីកើតនៃពួកទេព្តា ដែលជាឧបបាតិកកំណើត សោយបីតិជាអាហារ ជាពួកទេព្តាមានតន្ទ្រីស្ម័គ្រដោយខ្លួនឯង ៗ នៅស្ថានព្រហ្មមាន ៤ ជាន់ ជាពួកព្រហ្មដែលហៅថាពួករូបព្រហ្ម ។ ស្ថានអរូបព្រហ្មមានតែពួកព្រហ្មដែលមានតែវិញ្ញាណឥតរូប មាន ៤ ជាន់ដែរ ពួក ៣ ជាន់ដំបូងជាពួកវិញ្ញាណដ្ឋិតិ ជាន់ទី ៤ ជាពួកសត្តាក់ស ។ នៅមានបក្រក់ឡូតូប ៗ ទៀតជាចំនួនរាប់សែនរាប់លានច្រើនលើសលន់គណនា ។

(ភ៩ក)

# អំពីការរៀបមង្គលការ

ការរៀបការនោះ ជាន់ដើមមិនព្រមឲ្យពួកប៉ាទ្រិស្យាននឹងពួកប្លេបេ-អ៊ីយ៉ានរៀបមង្គលការជាមួយគ្នាទេ ការរៀបការសម្រេចទៅតាមទំនៀមសាសនាទាំងអស់ ៗ លុះតមក ពួកប្លេបេអ៊ីយ៉ានមានអំណាចស្មើនឹងពួកប៉ាទ្រិស្យាន ការរៀបការទើបក្លាយទៅជានិតិកម្មមួយឡើង (សម្រេចទៅតាមច្បាប់អាណាចក្រ) ៗ ការរៀបមង្គលការនេះ កាលបើមានហេតុត្រូវលែងលះគ្នា ត្រូវស្វាមីប្រគល់ទ្រព្យសម្បត្តិ ១ ជុំទុកក្នុងដៃរបស់ភរិយាសម្រាប់ចិញ្ចឹមជីវិត (ទំនៀមនេះដូចអាថែន្ស) ៗ ការលែងលះគ្នានេះ កាលជាន់ដើមនោះមិនសូវមានជាញឹកញាប់ទេ ព្រោះច្បាប់ជាន់ដើមបើកអំណាចឲ្យស្វាមីបណ្ដេញភរិយាចេញបាន ហើយក្នុងករណីដែលស្វាមីមិនទាន់បណ្ដេញនោះ ទុកជាភរិយាបានសេចក្ដីលំបាកតោកយ៉ាកយ៉ាងណា ក៏ត្រូវតែនៅនឹងស្វាមីរបស់ខ្លួនជាដរាប ៗ លុះតមក មានច្បាប់បើកអំណាចឲ្យប្រពន្ធប្ដីលែងលះដោយខ្លួនឯងបាន ការលែងលះគ្នាក៏មានក្រាស់ឡើងជានិច្ច គឺមានញឹកណាស់ តាល់តែមានអ្នកប្រាជ្ញរោម៉ាំងម្នាក់ពោលទុកថា "ស្ត្រីមានពូជអំបូររបស់រោម៉ាំងនោះ បាន

លែងលះប្ដីរបស់ខ្លួនដើម្បីទៅរៀបការនឹងបុរសថ្មីទៀត ហើយការរៀបការថ្មីនេះដើម្បីលែងលះគ្នាតទៅទៀត....” ។

កាលបើកូនកើតឡើង តោងឪពុកទទួលកប់រងជាកូនទើបត្រឹមត្រូវតាមច្បាប់ ហើយការទទួលកប់រងនេះតោងធ្វើក្នុងរវាង ៧ ថ្ងៃ រាប់តាំងអំពីក្មេងនោះកើតមក ហើយនៅខណៈដែលឪពុកទទួលកប់រងនេះ មានការតាំងឈ្មោះក្មេងនោះព្រមជាមួយគ្នាផង ឪពុកមិនសូវរវល់នឹងការចិញ្ចឹមកូនទេ ហើយត្រូវនៅនឹងដៃម្ដាយរហូតដល់ពេលត្រូវបញ្ជូនខ្លួនទៅចូលសាលារៀន ។ វិជ្ជាដែលបង្រៀនក្នុងសាលានោះគឺការរៀនមើល, រៀនសរសេរ នឹងរៀនលេខ ។ ចំណែកឯគ្រូអាចារ្យនោះច្រើនតែកាចណាស់ ធ្វើទោសវាយដំជានិច្ច ។ បើជាកូនអ្នកមានទ្រព្យធនគ្រាន់បើក៏ជួលគ្រូមកបង្រៀននឹងផ្ទះ កាលបើបានរៀនវិជ្ជាជាន់ដើមរួចហើយត្រូវរៀនខាងអក្សរសាស្ត្រទៅទៀត គឺទន្ទេញកាព្យឃ្លោងដែលជាភាសាក្រិកនឹងឡាតាំង ហើយកិច្ចដែលមិនត្រូវខានគឺការទន្ទេញគួបខមាត្រាច្បាប់ដែលហៅថាច្បាប់ ១២ តុ គឺជាច្បាប់ដែលគេសរសេរលើតុថ្មទាំង ១២ ការកត់ត្រាច្បាប់លើតុថ្ម មានមូលហេតុដើមដំណាលទុកថា កាលបើពួកប៉្លេបេអ៊ៀងកំពុងខំប្រឹងឲ្យមានសិទ្ធិអំណាចស្មើនឹងពួកប៉ាទ្រិ-ស្យាំងនោះ ច្បាប់ពេម៉ាំងនេះមានការដឹងឮបេះដឹងតែក្នុងពួកប៉ាទ្រិ-

សាន់ប៉ុណ្ណោះ  សម្រាប់លើកឡើងប្រើធ្វើទោសពិន័យដល់ពួកប៉្លេបេអ៊ី-យាន់ៗឥតចេះដឹងច្បាប់នេះឡើយ ។ លុះពួកប៉្លេបេអ៊ីយាន់មានសិទ្ធិអំ-ណាចឡើងហើយ ទើបប្តឹងសុំឲ្យសរសេរច្បាប់ជាអក្សរឲ្យមនុស្សចេះ-ដឹងគ្រប់គ្នាឡើង ទើបបានជាគេឆ្លាក់ច្បាប់អស់នេះលើតុ ១២ តុ ហៅថា ច្បាប់ ១២ តុ ។

## អំពីពួកទាសា-ទាសី

ពួកខ្ញុំកំដរជាពួកដែលមុខគួរសង្វេគស្លុតចិត្តជាទីបំផុត ក្នុងពង្សាវតារ របស់រ៉ូម៉ាំង ព្រោះពួកមនុស្សដែលជាខ្ញុំគេនោះ មិនមែនគេទុកដាក់ជា មនុស្សតាមច្បាប់ឡើយ ហើយមិនមានសិទ្ធិអំណាចក្រៃលែងជាងសត្វដំរី, សេះ, ក្របី, គោ ដែលជាសវិញ្ញាណកទ្រព្យសោះឡើយ នៅក្នុងពេលពុទ្ធ-សករាជ ៥០០ ឆ្នាំ ពួកខ្ញុំកំដរមានចំនួនដល់ ៩០០.០០០ នាក់នៅក្នុង ក្រុងរ៉ូម ជាពួកដែលមានសេចក្តីលំបាកវេទនាជាបំផុត ។ ប្រជាជនអ្នក ស្រុកតាមធម្មតា ទុកជាទាល់ក្រយ៉ាងណាក៏គង់មានខ្ញុំប្រើដែរ បើជា មនុស្សមានសម្បត្តិស្តុកស្តម្ភ សឹងមានខ្ញុំប្រើជាចំនួនច្រើនមានចំនួនដល់ ទៅ ២០.០០០ នាក់ក៏មាន ពួកខ្ញុំអស់នោះមានតាំងលក់នៅតាមផ្សារ ពួក អ្នកជំនួញលក់ខ្ញុំបានកៀរប្រមូលពួកខ្ញុំមកលក់នៅទីផ្សារតាំងហូងៗ ដូច ជាសត្វមាន់, ទា មានស្លាកចងព្យួរនឹងកប្រាប់ឲ្យដឹងអាយុ, ជាតិ, វិជ្ជា

ចំណោះរបស់ខ្ញុំអស់នោះ ៗ ពួកជនជាតិកេម៉ាំងមានទិស្ស័យសន្ដានចិត្តសាហាវជាងពួកក្រិក ហេតុនេះពួកខ្ញុំរបស់កេម៉ាំងបានទទួលសេចក្ដីលំបាកវេទនាលើសលែងជាងពួកខ្ញុំរបស់ក្រិក ៗ បើខ្ញុំណាមានចំណេះវិជ្ជាគ្រាន់បើ ដូចជាចេះបង្រៀនអក្សរ, ចេះភ្លេង, ចេះធ្វើជាង, ធ្វើគ្រូមើលជម្ងឺ ក៏បានធូរបន្ដិចមិនលំបាកពេក ៗ មានខ្ញុំកំដរខ្លះធ្វើឲ្យនាយចៅហ្វាយស្រឡាញ់ពេញចិត្តច្រើន ឬជួនជាទៅប្រទះលើនាយចៅហ្វាយដែលមាន មេត្តាករុណា ទើបមានឱកាសរួចជាអ្នកជាបាន ៗ ពួកខ្ញុំដែលបានរួចខ្លួនជាអ្នកជាហើយនោះ នៅតែមិនមានសិទ្ធិអំណាចជាអ្នកស្រុកសុទ្ធ ៗ នៅឡើយ ទុកជាកូនរបស់ខ្លួនក៏នៅតែមិនទាន់បាន លុះដល់ចៅចៅទើបមានសិទ្ធិអំណាចស្មើនឹងប្រជាជនទាំងឡាយ ព្រោះឈាមជ័ររបស់ខ្ញុំនោះសាបលោបអស់ទៅជាច្រើនណាស់ហើយ ៗ

## អំពីការធ្វើបុណ្យសព

ការធ្វើបុណ្យសពជាពិធីសំខាន់ ១ មានការហែហមសពដូចជាពួកក្រិកដែរ តែមានការចំឡែកប្លែកពីពួកឱរុបជាតិឯទៀត គឺសពរបស់ពួកកេម៉ាំងមិនបានកប់ទេ ប្រើដុត (ដូចជាខ្មែរយើង) ហើយរើសប្រមូលយកឆ្អឹង ធ្យូងទៅទុកនៅទីសក្ការបូជារបស់គ្រួសារ ៗ ប្រសិនបើខ្មោចនោះជាមនុស្សមានបុណ្យស័ក្ដិមានសម្បត្តិច្រើនក៏កសាងទីកន្លែងសម្រាប់ដំកល់កោដ្ឋឆ្អឹងធ្យូងនោះយ៉ាងធំសំបើម ៗ

ជនជាតិកេមុាំងនេះបានពោលមកពីខាងដើមហើយថាជាពួកដែលចិញ្ចឹមជីវិតយ៉ាងងាយៗស្រួលៗ លុះមកដល់សម័យពួកកេមុាំងមានជ័យជំនះជាតិឯទៀតៗហើយនាំយកបែបផែនសង្ហាហ៊ឹកហាក់មកពីស្រុកក្រិកនិងស្រុកដទៃទៀតនៅទិសខាងកើត ហេតុនេះបានជាគ្រាក្រោយៗមកពួកកេមុាំងក៏ក្លាយទៅជាពួកហឹហាខ្លះខ្លាយពន់ពេក ។

ក — អំពីការត្រួតត្រាស្រុក — ឯច្បាប់សម្រាប់ត្រួតត្រាស្រុករបស់ពួកកេមុាំងនោះ ក៏ប្រហែលៗនឹងច្បាប់របស់ក្រិកជាច្រើន ពោលគឺមានទីប្រជុំធំសម្រាប់ជាទីប្រមូលពួករដ្ឋបុរស មានសភាសេណាត៍សម្រាប់វិនិច្ឆ័យសម្រេចច្បាប់នីមួយៗដោយវិធីបោះឆ្នោត ។ ឯការបោះឆ្នោតក្នុងសភាសេណាត៍នេះ ប្រើវិធីប្លែកពីធម្មតា គឺមិនមែននាំឆ្នោតទៅដាក់នៅទីណាមួយឬប្រើវិធីលើកដៃទេ តែគេនិយមធ្វើដោយវិធីក្រោកឡើងទៅឈររួមគ្នាជាពួកៗជា ២ ពួក គឺពួកដែលយល់ព្រម ១ ពួក ពួកដែលយល់ទាស់ ១ ពួក ទើបគេរាប់ចំនួនមើលតើខាងណាច្រើនជាង ។ ក្រៅពីនេះនៅមានសភា ១ ទៀតជាសភាសំខាន់ណាស់ដែរ មានលក្ខណៈជាសភាជំណាងរាស្ត្រ ពោលគឺការរើសតាំងអ្នកជំណាងរាស្ត្រចូលទៅប្រជុំក្នុងសភានោះនេះក៏មានវិធីជាចំឡែកណាស់ដែរ ពោលគឺរាស្ត្រដែលបោះឆ្នោតនោះគេឱ្យកាន់ឆ្នោតដើរស្ពានតូចៗទៅម្ដងម្នាក់ ហើយយកឆ្នោតទៅដាក់នៅទីទទួលឆ្នោត ដែលតាំងនៅចុងស្ពានខាងឯណោះ ។

(មានត)

# សេចក្ដីប្លែក ៗ

អស្សឃោសៈ — ជាឈ្មោះមហាកវីឯកខាងពុទ្ធសាសនាមហាយាន ដែលជនជាតិខ្មែរយើងត្រូវតែស្គាល់ឈ្មោះរបស់លោក ដ្បិតលោកនេះបានតែងកាព្យឆន្ទយ៉ាងវិសេស ១ ជាភាសាសំស្ក្រឹត និយាយអំពីពុទ្ធប្បវត្តិ ។ នៅថ្ងៃមួយយើងនឹងប្រែកាព្យនេះមកជាភាសាខ្មែរ ដើម្បីជាប្រយោជន៍ដល់កូនសិស្សសាលាបាលីជាន់ខ្ពស់ ដែលរៀនសូត្រខាងភាសាសំស្ក្រឹត ។

លោកអស្សឃោសៈជាអ្នកតែងគម្ពីរវិសេស ១ សុទ្ធតែជាគាថា ហៅថា "ពុទ្ធចរិតៈ" ក្នុងសម័យសព្វថ្ងៃនេះ ប្រទេសឥរុបគេបានប្រែចេញជាភាសាផ្សេងៗ ស្ទើរតែគ្រប់ភាសា លោកអស្សឃោសៈ តាំងអំពីលោកផ្លាស់ចិត្តគំនិតមកកាន់ព្រះពុទ្ធសាសនា លោកតាំងចិត្តជាអ្នកផ្សាយពង្រីកព្រះពុទ្ធសាសនាដោយវិធីផ្សេងៗ មិនមែនគ្រាន់តែធ្វើជាធម្មកថិកមួយអង្គ ដែលល្បីល្បាញប៉ុណ្ណោះទេ លោកធ្វើជាកវីឯកទៀតផង ។ កិច្ចការដោយដៃរបស់លោកមានច្រើនណាស់ តែពួកអ្នកប្រាជ្ញខាងទ្វីបឥរុប និងទ្វីបអាស៊ីបានចង្អុលបង្ហាញថាមានប្រភេទខ្លះមិនមែនជារបស់លោកទេ ដ្បិតមានសេចក្ដីកាន់ច្រឡំអំពីឈ្មោះអ្នកតែងគម្ពីរ ដែលមានឈ្មោះដូចគ្នានេះក៏មានជាច្រើន ក្នុងសម័យផ្សេងៗគ្នា ។ លោកអ្នកប្រាជ្ញដែលតែងគម្ពីរពុទ្ធចរិតនោះ នៅក្នុងសម័យនៃពុទ្ធសករាជ ៦៥០ ឆ្នាំ ក្រោយព្រះពុទ្ធបរិនិព្វាន ។

បាហ៊ុតៈ – បុរាណស្ថានពុទ្ធសាសនា តែពាក្យនេះជាឈ្មោះភូមិតូច ១ នៅក្នុងប្រទេសឥណ្ឌាខាងជើង មានកេរ្តិ៍ឈ្មោះល្បីឡើងដោយសារមានព្រះចេតិយដែលជនជាតិអង់គ្លេសម្នាក់បានរកឃើញក្នុងពុទ្ធសករាជ ២៤១៦ ។ ព្រះចេតិយនេះមានទ្រង់ទ្រាយមូល មានរាជវតិព័ទ្ធជុំវិញ មានទ្វារចេញទៅក្នុងទិសទាំង ៤ ហើយពាសពេញទៅដោយក្បាច់ចម្លាក់ទាំងអស់ ក្នុងទ្វារនីមួយៗនោះមានក្បាច់ចម្លាក់យ៉ាងល្អឆើតព្រមទាំងគ្រឿងធៀបប្រដូចខាងពុទ្ធសាសនា មានផ្ទាំងផ្កាឈូកនិងរឿងរ៉ាវជាតកផ្សេងៗ ហើយនៅក្នុងចំណោមរឿងពុទ្ធប្បវត្តិនោះ មានមួយអន្លើគេដឹងច្បាស់ថា រឿងអនាថបិណ្ឌិកសេដ្ឋីទិញវិហារជេតវ័នថ្វាយព្រះអង្គ ។ អស់ទាំងក្បាច់ឆ្លាក់ក្រោមជាក្បាច់ល្អៗណាស់ ចង្អុលឲ្យយើងដឹងថាការចិញ្ចឹមជីវិតរបស់មនុស្សសម័យដែលគេសាងបុរាណស្ថានៗនេះកើតឡើងកាលពីពុទ្ធសករាជ ៣៤៣ ។ ក្បាច់ចម្លាក់នៅទឹងចេតិយនេះមិនមានព្រះពុទ្ធរូបទេ គេធ្វើគ្រឿងធៀបដទៃទៀតជាតំណាងរូបព្រះបរម-គ្រូ ដូចជាស្នាមព្រះពុទ្ធបាទ, កង់ចក្រ, បល្ល័ង្ក, ទេនជាទីធ្វើសក្ការបូជាមានស្វេតច្ឆត្រនៅពីលើ ។ ឯរូបឧបាសកឧបាសិកាទាំងឡាយគេធ្វើជារូបសំដែងសេចក្ដីគោរពដល់រូបធៀបអស់នោះ ។ ទ្វារមួយនឹងរាជវតិមួយចំណែក គេយកទៅដាក់ទុកក្នុងសារមន្ទីរកល់គុត្តា ។

(នៅមានត)

# រឿងបុរសពីរនាក់ទៅរកបរបាញ់

មាននិទានមួយដំណាលថា មានបុរសពីរនាក់ទៅរកបរបាញ់ លុះបានឃើញសត្វហើយ ក៏បាញ់ព្រមគ្នាត្រូវសត្វនោះងាប់ហើយគិតនឹងអារចែកគ្នា ៗ បុរសទាំងពីរសឹងកើតចិត្តលោភចង់បានចំណែកលើសគ្នាតែរៀងខ្លួន ប្រកែកគ្នាទៅវិញទៅមកពុំដាច់ស្រេចឡើយ ហើយបបួលគ្នាសែងសត្វនោះយកទៅប្តឹងចៅក្រម ដល់ហើយបុរសមួយនិយាយថា សូមជំរាបលោក ដ្បិតយើងខ្ញុំទាំងពីរនាក់នេះបាញ់ត្រូវសត្វនេះព្រមគ្នា លុះសត្វនេះងាប់ហើយ គិតនឹងអារសាច់ចែកគ្នា ស្រាប់តែមានពាក្យវ៉ៃទ ទៅវិញទៅមក ចង់យកចំណែកលើសតែរៀងខ្លួន សេចក្តីនេះសូមលោកចែកឲ្យយើងខ្ញុំហោង ៗ ទើបចៅក្រមដណ្តឹងសួរថា នរណាបាញ់ត្រូវមុន នរណាបាញ់ត្រូវក្រោយ បុរសមួយថា បាញ់ត្រូវព្រមគ្នាតែខ្ញុំប្របាទបាញ់ត្រូវត្រង់ទ្រូង ឯចៅនេះបាញ់ត្រូវជើងទាំងពីរ ៗ បុរសមួយទៀតឆ្លើយថា បាញ់ត្រូវព្រមគ្នាតែខ្ញុំប្របាទបាញ់ត្រូវបាក់ជើងទាំងពីរ ចៅនេះបាញ់ត្រូវទ្រូងមែន ៗ ឯចៅក្រមនិយាយថា បើតាមពាក្យចៅទាំងពីរនេះឆ្លើយឲ្យការឃើញថាបាញ់ត្រូវព្រមគ្នាមែន បើដូច្នេះអញបង្គាប់ឲ្យចៅទាំងពីរកាត់ក្បាលទុកជាខាត់ ឯខ្លួនសត្វនោះត្រូវពុះជាពីរ អញនឹងពិចារណាមើល ជាគួរចែកគ្នាម្ខាងម្នាក់ឬយ៉ាងណា ៗ ចៅ

ទាំងពីរពុំព្រមធ្វើតាមចៅក្រមបង្គាប់នោះឡើយ ទើបចៅក្រមនាំចៅទាំងពីរនោះឡើងក្រាបបង្គំទូលសម្តេចព្រះមហាក្សត្រាធិរាជ ព្រះអង្គជ្រាបដោយដំណើរសព្វគ្រប់ហើយ ទើបទ្រង់មានព្រះបន្ទូលថា ដោយសារព្រះស្នែងបាញ់ត្រូវដើមទ្រូងបានជាសត្វនោះងាប់ឆាប់ ឯព្រះស្នែងបាញ់ត្រូវបាក់ជើងទាំងពីរនោះ លុះតែធ្វើទុក្ខថែមទៀតទើបអស់អាយុសត្វនោះ ទើបព្រះអង្គឲ្យយកសត្វនោះទៅអារសាច់ចែកជាភាគបី ភាគពីរឲ្យបានទៅចៅបាញ់ត្រូវដើមទ្រូង ភាគមួយឲ្យបានទៅចៅបាញ់បាក់ជើងទាំងពីរនោះហោង ។ ការដែលសម្តេចព្រះមហាក្សត្រាធិរាជព្រះអង្គបង្គាប់ឲ្យចែកដូច្នេះនេះ ចៅទាំងពីរចូលចិត្តព្រមគ្នាហើយក្រាបថ្វាយបង្គំលាវិលទៅលំនៅទីទៃ ៗ ហោង ។